**សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ**
**និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង**
**សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន**
**"គម្រោងលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមជនបទក្នុងប្រទេសកម្ពុជា**
**ដំណាក់កាលទី៣"**
**ថ្ងៃទី ២៥ ខែធ្នូ ២០១៥**
**នៅ សាលប្រជុំធំ ស្ថានទូតជប៉ុន**

- សូមគោរព អង្គការសន្តិស្ម័គ្រចិត្ត!
- សូមគោរព លោក តាម៉ារិ គីយ៉ូតាកា នាយកអង្គការសន្តិស្ម័គ្រចិត្ត!
- សូមគោរព អស់លោក លោកស្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនគឺ "គម្រោងលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមជនបទក្នុងប្រទេសកម្ពុជា ដំណាក់កាលទី៣"។

អង្គការសន្តិស្ម័គ្រចិត្ត (SVA) បាននិងកំពុងធ្វើការគាំទ្រដល់សកម្មភាពជាច្រើនអស់រយៈកាលជាង៣0ឆ្នាំមកហើយក្នុងប្រទេសកម្ពុជា ហើយរដ្ឋាភិបាលជប៉ុនក៏បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គការរហូតមកដែរ។ ខ្ញុំដឹងថា អង្គការសន្តិស្ម័គ្រចិត្ត (SVA) ផ្តោតសំខាន់លើវិស័យអប់រំ និងការអភិវឌ្ឍធនធានមនុស្ស ហើយខ្ញុំសង្ឃឹមថា គម្រោងលើកនេះក៏នឹងបន្តរួមចំណែកយ៉ាងធំធេងដល់កំណើននៃអត្រាអ្នកចេះអាននិងចេះសរសេរដើម្បីពង្រឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ។

ក្រសួងអប់រំ យុវជន និងកីឡា យោងតាមកម្មវិធីពង្រីកការអប់រំក្រៅប្រព័ន្ធរបស់ផែនការយុទ្ធសាស្ត្រអប់រំកំពុងតែរៀបចំបរិស្ថាន អប់រំអក្ខរាវិទ្ធ នៅតាមមជ្ឈមណ្ឌលសិក្សាតាមជនបទ ក្នុងគោលដៅបំពេញនូវការអប់រំអក្ខរាវិទ្ធដល់យុវជន និងមនុស្សពេញវ័យ ។ គម្រោងរបស់អង្គការសន្តិស្ម័គ្រចិត្តនេះ ត្រូវបានលើកឡើងជាឧទាហរណ៍មួយដែលទទួលបានជោគជ័យ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំនេះរបស់ក្រសួងខាងលើ។ ហើយគម្រោងនេះផងដែរ ត្រូវបានចុះផ្សាយដោយអ្នកសារព័ត៌មានទាំងនៅក្នុងប្រទេសកម្ពុជា ទាំងនៅប្រទេសជប៉ុនមានចំនួនច្រើន សរុបជាង១០ព័ត៌មាន។

មជ្ឈមណ្ឌលសិក្សាសហគមន៍(CLC)ចំនួន៥កន្លែង នៅក្នុង៣ខេត្ត ត្រូវបានសាងសង់ឡើងក្រោមការអនុវត្តនូវគម្រោងក្នុងឆ្នាំទី១ និងឆ្នាំទី២។ ហើយមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងនេះ មិនត្រឹមតែទទួលបានជំនួយផ្នែករឹងតែប៉ុណ្ណោះទេ តែក៏បានទទួលនូវការពង្រឹងឡើងនូវប្រព័ន្ធរវាងក្រសួងអប់រំ និងមន្ទីរអប់រំ ហើយគណៈកម្មាធិការCLC ដែលជាចំណុចកណ្ដាលរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ ក៏ទទួលបាននូវការបង្រៀនពីរបៀបគ្រប់គ្រង ដើម្បីរៀបចំជាប្រព័ន្ធមួយសម្រាប់ឯករាជ្យភាពរបស់មជ្ឈមណ្ឌល ក្រោយពេលគម្រោងត្រូវបានបញ្ចប់។ ខ្ញុំបានទទួលដំណឹងថា អត្រាចូលរួមសិក្សាជាមធ្យមរបស់សាលាអប់រំអក្ខរកម្មទូទៅមានចំនួនពី ២០% ទៅ ៥០% រីឯCLC ចំនួន៣ មជ្ឈមណ្ឌលរបស់គម្រោងនេះ មានអត្រាចូលរួមសិក្សាជាមធ្យមចំនួន ៨៤%។

ខ្ញុំបានដំណឹងទៀតថា ក្នុងឆ្នាំទី៣នេះ មានការបើកសម្ពោធនូវមជ្ឈមណ្ឌលCLC ថ្មីមួយ នៅឃុំតាអាន ខេត្តសៀមរាប ហើយនឹងមានថ្នាក់បង្រៀនអក្ខរកម្មសម្រាប់ប្រជាពលរដ្ឋប្រមាណ ៤២៨១ នាក់ ជាពិសេសជួយពួកគាត់ឲ្យមានឱកាសក្នុងការសិក្សាចំណេះវិជ្ជាទាក់ទងទៅនឹងវិស័យកសិកម្មផងដែរ។ យោងតាមជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៣ អត្រាចេះអក្សរ របស់ខេត្តសៀមរាបដែលជាគោលដៅគម្រោងយើងនេះមានចំនួន ៦៧,៤% ហើយអត្រាជាមធ្យមទូទាំងប្រទេសមានប្រមាណក្រោម ៦៩,៧%។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភឥតសំណង ទាក់ទងជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានផ្ដល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច ដែលត្រូវអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដើម្បីឲ្យមានប្រយោជន៍ដោយផ្ទាល់ដល់កំរិតថ្នាក់មូលដ្ឋាន។ ខ្ញុំសង្ឃឹមថា គម្រោងដែលត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ នឹងផ្ដល់ជាផលប្រយោជន៍ដោយផ្ទាល់ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់គោលដៅ ហើយមជ្ឈមណ្ឌលអប់រំសហគមន៍ ដែលត្រូវបានសាងសង់ឡើងក្រោមការជ្រោមជ្រែងរបស់អ្នកទាក់ទងរដ្ឋបាល នឹងត្រូវបានថែរក្សាឲ្យបានគង់វង្សយូរអង្វែង និងត្រូវបានប្រើប្រាស់ឲ្យមានប្រសិទ្ធភាពពេញលេញ។

**សូមអរគុណ!**